**សកម្មភាព** ៖ **ល្បែងទាយវត្ថុដែលបា**

**វិទ្យាសាស្រ្ត**

ការរស់នៅប្រចាំថ្ងៃ (ការស្វែងយល់ដោយសង្កេត)

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង** ៖

**(វិទ្យាសាស្រ្ត)** ប្រាប់បានពីរបៀបនៃការពិសោធន៍។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ អ្នកអាចស្វែងរកវត្ថុផ្សេងៗដែលមាននៅក្នុងថ្នាក់រៀនក៏បាន។

- វត្ថុដែលមានពណ៌ផ្សេងគ្នា ឬរូបភាព
- ក្រណាត់ធំល្មមដែលអាចគ្របវត្ថុនោះបាន

**ការរៀបចំ៖** រៀបចំវត្ថុមួយចំនួន និងគ្របវាដោយក្រណាត់

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែងរបស់គឺមជាមួយកូនៗទាំងអស់គ្នា។
2. អ្នកគ្រូបង្ហាញវត្ថុដែលមានពណ៌ផ្សេងគ្នា ឬរូបភាព ក្រណាត់ធំល្មមដែលអាចគ្របវត្ថុនោះបាន។
3. ឧទាហរណ៍៖ នេះជាសៀវភៅពណ៌ខៀវ បន្ទាត់ពណ៌ក្រហម ខ្មៅដៃពណ៌លឿង …។
4. ឱ្យក្មេងៗថាតាមទាំងអស់គ្នាដើម្បីឱ្យក្មេងៗមានការចងចាំ ។
5. បន្ទាប់មក ត្រូវលាក់វត្ថុទាំងនោះនូវក្រោមក្រណាត់។
6. រួចផ្លាស់ប្តូរវត្ថុមួយដោយមិនឱ្យក្មេងៗបានដឹងនោះទេ ថាវត្ថុមួយណាដែលត្រូវបានផ្លាស់ប្តូរ។
7. ចាប់យកក្រណាត់ដែលរុំវត្ថុមួយមកហើយសួរក្មេងៗថា តើវត្ថុមួយណាដែលបានបាត់។
8. ក្មេងៗអាចនិយាយឈ្មោះវត្ថុដែលបាត់នោះ។
9. អ្នកគ្រូធ្វើបែបនេះច្រើនដងរហូតដល់ល្បែងនេះបានបញ្ចប់ ។

**ការប្រែប្រួល៖**

- ❖ ល្បែងនេះលោកគ្រូ អ្នកគ្រូអាចលេងដោយប្រើវត្ថុជំនួសពណ៌បាន (ឧទាហរណ៍. រូបសត្វ ឬ បន្លែ)។
- ❖ ល្បែងនេះអាចប្រែប្រួលទៅតាមអាយុ ដោយប្រើឧបករណ៍តិច ឬក៏ច្រើន។
- ❖ លោកគ្រូ អ្នកគ្រូអាចផ្លាស់ប្តូរឧបករណ៍ចាប់ពីម្តងពីរបាន ឬ មិនបាច់ដកវត្ថុអ្វីចេញសោះក៏បានដែរ ដើម្បីឱ្យដឹងថាពួកគេមានការចងចាំបានល្អ។

**កត់សម្គាល់:**

ល្បែងនេះអាចនឹងសប្បាយ ដោយប្រើឆ្នាំសត្វទាំង១២ទាក់ទងនឹង «រឿងសួរស្តីឆ្នាំថ្មី»។